# ព្រះរាជក្រឹត្យ

នស/រកត/១១១៨/ ១២៣៥

## ស្ដីពី

## វិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ស្ដីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្ដីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្ដីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ស្ដីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

ត្រូវបានធ្វើវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០១១/៩៤១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដូចតទៅ៖

**មាត្រា១ ថ្មី.-**

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- ឥស្សរជនមួយរូប | អនុប្រធានប្រចាំការ |
| ៣- រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៤- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៧- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១- រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១២- រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥- រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១៦- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១៧- អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ សមាជិក

១៨- តំណាងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សមាជិក

១៩- មេធាវីរាជរដ្ឋាភិបាល សមាជិក

២០- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត សមាជិក

សមាសភាពជាក់ស្តែងនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ ថ្មី.-**

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានទីតាំងនៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការចំណាយក្នុងកិច្ចដំណើរការរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ជាបន្ទុកថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រាពីរ.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៨*

ចកសរ.១៨១១.១២៥០

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**